ព្រឹត្តប័ត្រព័ត៌មាន អេកូសន

ECOSORN NEWSLETTER

លេខទី ៤, ខែ តុលា ឆ្នាំ ២០០៨

Issue 4, October 2008



*សិស្សានុសិស្សនឹងទទួលបានឱកាសយល់ដឹងអំពីសុវត្ថិភាពដីធ្លី*
*Students will have an opportunity to gain understanding of safeguarding land*

# សុវត្ថិភាពនៃការប្រើប្រាស់ដីធ្លី

កិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើអោយការកាន់កាប់ដីធ្លីឱ្យកាន់តែមានសុវត្ថិភាពប្រសើរឡើង រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ភូមិបាលឆ្នាំ ២០០១ ដែលក្នុងនោះបានបង្កើតឡើងនូវប្រព័ន្ធមួយហៅថា "ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រពន្ធ័" ។ ស្ថិតនៅក្រោយច្បាប់ភូមិបាលនាឆ្នាំ ២០០១ ក្បាលដីទាំងអស់នៅក្នុងផ្ទៃប្រទេស( តាមការប៉ាន់ប្រមាណមានពី ១០ ទៅ ១២លានក្បាលដី) នឹងត្រូវចុះបញ្ជីតាមរយៈការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។ ក្រោយពេលដែលបានចុះបញ្ជីរួច ម្ចាស់ដីត្រូវបំពេញឯកសារនៃការកំណត់ព្រំដី តាមបែបបទនៃការចុះបញ្ជីដីធ្លីនៅការិយាល័យចុះបញ្ជីដីធ្លី ហើយនឹងមានការចេញប័ណ្ណកម្មសិទ្ធិដីដែលទទួលស្គាល់ដោយរដ្ឋ ។

ចាប់តាំងពីការចេញប័ណ្ណកម្មសិទ្ធិដីក្នុងដំណើរការនេះមក គឺមិនមានករណីប្រកែកតវ៉ាបានឡើយ ហើយប្រសិនបើមានវិញគឺតិចតួចបំផុត ។ ការចុះបញ្ជីលើកដំបូង និង ការចុះបញ្ជីបន្តបន្ទាប់ត្រូវបានប្រគល់អោយការិយាល័យចុះបញ្ជីដីធ្លី ដែលនឹងបង្កើននូវ សុវត្ថិភាពរបស់កម្មសិទ្ធករ ហើយនឹងកាត់បន្ថយ និងការពារជម្លោះដីធ្លីនៅក្នុងប្រទេស ។

បច្ចុប្បន្នបញ្ហាដីធ្លីជាបញ្ហាដ៏ចំបងមួយដែលត្រូវធ្វើការដោះស្រាយដោយខានមិនបាន ។ មានបណ្តាស្ថាប័នពាក់ព័ន្ធជាច្រើនចូលរួមបង្កើនចំណេះដឹងពីបញ្ហាទាំងនេះ ទៅដល់ប្រជាពលរដ្ឋនៅតាមសហគមន៍ ។

*តទៅទំព័រទី២*

## Safeguarding Land

In every effort put to further upgrading land tenure the Royal Government of Cambodia enacted the 2001 land law in which a new systematic registration is adopted. Under 2001 land law all land parcels in the whole country (estimated 10-12 millions land parcels) are registered through Systematic Land Registration by the Ministry of Land Management, Urban Planning and Construction. After the land registered the land proprietor has to fill the documents of the land demarcation in procedure of the land registration at the Land Registration Office, and then the land titles will be issued by the state.

Since land titles have been issued in the procedure there is unable to complain but in minor cases. For inertial and consequent registrations to offer the Land Registration Office safety to the possessors, alleviating and preventing land conflict and dispute in the region.
Recently the land becomes a vital issue that is inevitable to be solved, in which there are a number of relevant institutions getting involved in promotion of awareness local communities.

Currently, educational area has to boost understanding of safeguarding land, land value among secondary and high school students.

**Continued on page 2**

គំរោងនេះប្រតិបត្តិដោយអេកូសន និងផ្តល់មូលនិធិដោយសហភាពអឺរ៉ុប និងរាជរដ្ឋាភិបាលកម្ពុជា

*Continued from page 1*

## Safeguarding...

The impact of the project is to respond to the real needs of the poor, the farmers and the females with small landholders.

The European Commission awards the contract to MoEYS to implement the Ecosorn project of development and implementation of school curricula of "safeguarding land" for target secondary and high schools, enhancing community's awareness of land issues to improve livelihoods, in support to the Government's Strategy.

The students from 43 target schools will have an opportunity to gain better understanding of safeguarding land and important of land.

The Safeguarding Lands curricula disseminate the information to beneficiaries from secondary and high schools to allow them to become their own land stewards in effectiveness with explicit understanding of their obligations and rights. In addition, to be aware of natural resource management, environmental concerns will contribute to sustainable use of the land, expecting from different activities that land certificates will be delivered to the hands of the beneficiaries. The titles will help facilitate to gain access to credit and stimulate land market.

The earlier to get aware of the importance of secure access to land the sooner will contribute to long-term sustainable activities of the project through collateral for gaining access to credit and investment. And will help to strengthen the young's capacity to improve the community's economy.

*តពីទំព័រទី១*

## សុវត្ថិភាពនៃការ...

វិស័យអប់រំត្រូវជំរុញអោយមានការយល់ដឹង អំពីសុវត្ថិភាពដីធ្លី តំលៃនៃដីដល់សិស្សានុសិស្សកម្រិតអនុវិទ្យាល័យនិងវិទ្យាល័យ ។ គំរោងនេះនឹងឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់ និងជាក់ស្តែងរបស់ប្រជាពលរដ្ឋក្រីក្រ កសិករ និងស្ត្រីដែលមានដីបន្តិចបន្តួច ។

ក្រសួងអប់រំ យុវជន និងកីឡាសហការជាមួយគំរោអេកូសនសំរាប់កម្មវិធីអភិវឌ្ឍជនបទចម្រុះ តាមរយៈការបង្កើតកម្មវិធីសិក្សាស្តីពីសារៈសំខាន់នៃដី និងការប្រើប្រាស់ដីធ្លីដោយសុវត្ថិភាព ។

គណៈកម្មការសហគមន៏អឺរ៉ុបបានផ្តល់កិច្ចសន្យាផ្ទាល់ដល់ក្រសួងអប់រំ យុវជន និង កីឡា ដើម្បីអនុវត្តគំរោងអេកូសនលើការបង្កើត និង អនុវត្តកម្មវិធីសិក្សា "សុវត្ថិភាពដីធ្លី" នៅតាមអនុវិទ្យាល័យ និងវិទ្យាល័យក្នុងតំបន់គោលដៅ ។



*សកម្មភាពនិពន្ធមេរៀន*

គោលបំណងនៃកិច្ចសន្យានេះគឺលើកកម្ពស់ការយល់ដឹងរបស់សហគមន៏អំពីបញ្ហាដីធ្លី ដើម្បីធ្វើអោយជីវភាពមានភាពប្រសើរឡើង តាមរយៈការបង្កើត និងអនុវត្តកម្មវិធីសិក្សាស្របតាមយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលកម្ពុជា ។

សិស្សានុសិស្សមកពី ៤៣



អនុវិទ្យាល័យ និងវិទ្យាល័យ នឹងទទួលបានឱកាសយល់ដឹងអំពីសុវត្ថិភាព ដីធ្លី ។

កម្មវិធីសិក្សា "សុវត្ថិភាពដីធ្លី " ផ្សព្វផ្សាយព័ត៌មានដល់សិស្សានុសិស្សមកពីអនុវិទ្យាល័យ និងវិទ្យាល័យ នឹងធ្វើអោយពួកគេប្រែក្លាយជាអ្នកកាន់កាប់ដីដោយមានប្រសិទ្ធភាព យល់ច្បាស់ពីកាតព្វកិច្ច និង សិទ្ធិដីធ្លី ។ ចំណេះដឹងលើការគ្រប់គ្រងធនធាន ធម្មជាតិ និងបញ្ហាបរិស្ថាន នឹងរួមចំណែកក្នុងការប្រើប្រាស់ដីធ្លីប្រកបដោយចីរភាព ។

តាមរយៈកម្មវិធីផ្សេងៗទាំងនេះសង្ឃឹមថាប័ណ្ណកម្មសិទ្ធិដីធ្លីនឹងមានដល់ដៃអ្នកទទួលផលជាក់ជាមិនខាន ។ ប័ណ្ណកម្មសិទ្ធិនេះនឹងជួយសម្រួលសេវាឥណទាន និងបង្កើនទីផ្សារដីធ្លី ។

ដូចនេះ ការយល់ដឹងពីសារៈសំខាន់ក្នុងការប្រើប្រាស់ដីធ្លី ប្រកបដោយសុវត្ថិភាព នឹងរួមចំណែក ទ្រទ្រង់និរន្តភាពយូរអង្វែងតាមរយៈវត្ថុបញ្ចាំ សំរាប់ទទួលបានសេវាឥណទាន និង ការវិនិយោគ ។ម្យ៉ាងទៀត អាចជួយពង្រឹងសមត្ថភាពយុវជនជំនាន់ក្រោយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៏ ។

This project is implemented by ECOSORN and funded by the European Union and the Royal Government of Cambodia

The views expressed in this publication do not necessarily reflect the views of the European Commission

# ការបោសសម្អាតមីន

កិច្ចសន្យាត្រូវបានផ្តល់ឱ្យស្ថាប័នស៊ីម៉ាក់ ដោយសហគមន៍អឺរ៉ុបដើម្បីដំណើរការសកម្មភាពសម្អាតមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅតំបន់គោលដៅអនុវត្តគំរោងអេកូសនដោយប្រើឧបករណ៍ដោះមីនចម្រុះដើម្បីឆ្លើយតបទៅនឹងតំរូវការផ្សេងៗដែលទាក់ទងទៅនឹងបញ្ហាមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។



មានលទ្ធផលលទ្ធផលធំចំនួនពីរដែលត្រូវអនុវត្តដោយស៊ីម៉ាក់: ទី១ គាំទ្រការអភិវឌ្ឍសហគមន៍ និង ទី២ ការបោសសម្អាតមីន។ អេកូសន-ស៊ីម៉ាក់បានផ្តល់ការបណ្តុះបណ្តាលដល់អជ្ញាធរមូលដ្ឋានពីយន្តការនៃការកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រាប់មីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលមានការចូលរួមពីសំណាក់បណ្តាញអ្នកស្ម័គ្រចិត្តនៅតាមមូលដ្ឋាន ដែលជាគណៈកម្មការមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។

ជំនាញការស៊ីម៉ាក់និងក្រុមការងារអេកូសន សហកាជាមួយក្រុមការងារផែនការសកម្មភាពកំចាត់មីន"ម៉ាពូ"នៅក្នុងខេត្តគោលដៅទាំងបីបានជ្រើសរើស និងកំណត់តំបន់មានមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដើម្បីសម្អាតមីនចេញក្នុងឆ្នាំ ២០០៨-២០០៩ ។

ការសម្អាតមីនគឺធ្វើឡើងស្របតាមតម្រូវការតាមផ្នែកអេកូសនរួមមានៈ ផ្នែកកសិកម្ម បសុសត្វ និង ជលផល



សកម្មភាព ដោះមីន ធ្វើបង្ហាញ អ្នកកាសែត

ផ្នែកហេដ្ឋារចនា សម្ព័ន្ធជនបទ ផ្នែកអភិវឌ្ឍសហគមន៍ យេនឌ័រ និង អភិវឌ្ឍជនបទ និង ផ្នែកសុវត្ថិភាដីធ្លី ។ លទ្ធផលដែលប្រមូលបានពីផ្នែកទាំងនេះគឺ ទាក់ទិននឹងតំបន់សង្ស័យថាមានមីននោះគឺកំពុងគ្របដណ្តប់លើផ្ទៃដី កសិកម្មដីសាងសង់ផ្លូវជនបទ និងដីសំរាប់សង់លំនៅដ្ឋានដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់ក្នុងការសម្អាតមីនចេញពីខេត្តគោលដៅទាំងបី អេកូសន-ស៊ីម៉ាក់បានដាក់ចេញជាផែនការកំចាត់មីនលើផ្ទៃដីទំហំ ៤០០ហិកតា។

ដើម្បីផ្តល់ចំណេះដឹងនិងធ្វើឱ្យប្រជាពលរដ្ឋគេចផុតពីការគ្រោះថ្នាក់ដោយសារមីនក្រុមការងារបានធ្វើការបណ្តុះ-បណ្តាលអំពីយុទ្ធសាស្រ្ត ការពារ និង ការកាត់បន្ថយគ្រោះថ្នាក់។ ជាពិសេស បើប្រទះឃើញមីន សូមកុំប៉ះពាល់ ហើយរាយការណ៍មកភ្នាក់ងារស៊ីម៉ាក់ រឺអាជ្ញាធមូលដ្ឋាន ។

## *Mine clearance*

Contract is awarded to CMAC by EC for implementing Ecosorn activities to get rid of mines and unexploded ordinance at the Ecosorn identified areas with various de-mining tools to response to the requirment which related to various mine/unexploded ordinance maters.

CMAC is undertaking implementation of two main results: Institutional Support and De-mining. For the Institution Support CMAC has been providing training to the local authorities on mine/unexploded ordinance risk reduction mechanism, carrying out to release mine suspected land to be used for cropping production.

CMAC experts and Ecosorn technical staff have worked with the Provincial Mine Action Planning Unit staff in all three target provinces to select mine/unexploded ordinances suspected areas for de-mining in 2008 and 2009.

The selection of mine/unexploded ordinance suspected areas to de-mining as required by Ecosorn groups: Agriculture Livestock and Fisheries; Rural infrastructure; Community Gender and Rural Development; and Safer Access to Land. Two main are found suspected areas cover the lands for agriculture, rural road and residence.

To meet the needs of three target provinces, ECOSORN-CMAC is in process of getting rid of mines/unexploded ordinances from the target areas of 400ha. In order to provide knowledge to avoid danger of mine/ unexploded ordinance the mine officer have provided training on risk reduction strategy to prevent and reduction risk cause by mine/UXO. Especially, when you saw mine/UXO please do not touch and report to CMAC or village authority immediately.

## *Rural Infrastructure*

Rural infrastructure development is a main goal of ECOSORN that help local people in remote areas more easily travelling and transporting their products to market, and gaining inexpensive transportation services.

The rural road and irrigation scheme have been awarded to KBH Co Ltd and Thy Loo Co Ltd for construction.
Through the research there are 80.1 Km of rural road were selected for rehabilitation.
The construction of rural road rehabilitation was launched in January 2008. During the period there are four roads being constructed and the other four on going to construct in 2009.

In June 2008, the rural road of 6,200 meters in Kok Rormeat commune has been completed and the others are in the progress of constructing such as 3,700 meters in Banteay Chmar commune, 4,000 meters in Slor Kram commune, and 5,307 meters in Kum Rou commune. When this road finished constructed, the beneficiaries find easier access to the market for exchange their crops and students are able to continue further study in secondary school, which is farther distance from home.

The villagers are very happy and they promise to keep maintaining the road, funded by the European Union and the Royal Government of Cambodia.

## ហេដ្ឋារចនាសម្ព័ន្ធផ្លូវលំជនបទ

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវលំជនបទជាទិសដៅចំបងមួយរបស់អេកូសនដែលជួយបង្កភាពងាយស្រួលក្នុងការធ្វើដំណើរដឹកជញ្ជូនផលិតផលពីជនបទដាច់ស្រយាលមកកាន់ទីផ្សារ ។ និងទទួលបានសេវាដឹកជញ្ជូន ដែលមានតំលៃថោក ។

ផ្លូវលំជនបទក្រាលគ្រួសក្រហម និង ប្រព័ន្ធធារាសាស្ត្រ ត្រូវបានម៉ៅការសាងសង់ដោយក្រុមហ៊ុន KBH និង Thy Loo ក្រោមកិច្ចសហការជាមួយ មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរធនធានទឹក អាជ្ញាធរ ភូមិ ឃុំ មន្ត្រីឯកទេសអេកូសន និង តំណាងសហគមន៍អឺរ៉ុប ។ តាមការសិក្សារស្រាវជ្រាវផ្លូវលំប្រវែង ៨០.១គីឡូម៉ែត្រ ត្រូវបានជ្រើសរើសសំរាប់ជួសជុលឡើងវិញ។

ការសាងសង់ផ្លូវបានចាប់ផ្តើមដំណើរការពីខែ មករា ឆ្នាំ២០០៨។ នៅក្នុងកំឡុងពេលនេះផ្លូវលំចំនួន ៤ខ្សែ កំពុងដំណើរការ រីឯ ចំនួន ៤ខ្សែផ្សេងទៀតនឹងចាប់ផ្តើមនៅឆ្នាំ ២០០៩ ។



មកដល់ខែមិថុនា គំរោងបានធ្វើផ្លូវលំមួយខ្សែនៅឃុំគោករមៀត ប្រវែង ៦.២០០ ម៉ែត្រ ចំណែកផ្លូវបីខ្សែទៀតកំពុងដំណើរការសាងសង់ដូចជានៅឃុំបន្ទាយឆ្មាប្រវែង៣.៧០០ម៉ែត្រ នៅឃុំស្លក្រាមប្រវែង៤.០០០ម៉ែត្រ និងនៅឃុំគំរូប្រវែង៥.៣០៧ម៉ែត្រ។ពេលធ្វើផ្លូវទាំងនេះរួចរាល់ ប្រពលរដ្ឋនឹងមានភាពងាយស្រួលគាត់អាចធ្វើដំណើរដឹកកសិផលទៅលក់ទីផ្សារ ទិញសំភារៈប្រើប្រាស់ផ្សេងៗ ជាពិសេស សិស្សអាចបន្តការសិក្សានៅថ្នាក់អនុវិទ្យាល័យដែលនៅឆ្ងាយពីភូមិ។ អ្នកភូមិសប្បាយ នឹងទទួលផ្លូវលំនេះណាស់។ គាត់បានសន្យាថានឹងជួយថែរក្សាឱ្យបានគង់វង្សដល់សមិទ្ធផលដែលបានផ្តល់មូលនិធិដោយសហភាពអឺរ៉ុប និងរាជរដ្ឋាភិបាលកម្ពុជា ។


**ការិយាល័យគំរោងខេត្តសៀមរាប**
**Project Office, Siem Reap**
Provincial Department of Agriculture, Wat Damnak Village,
Salakamroek Commune, Siem Reap district, Siem Reap Province
P.O Box: 93241 Siem Reap Angkor
Tel: 063 965 478 - Fax: 063 761 243
Email: siem.reap.office@ecosorn.org

**ការិយាល័យគំរោងខេត្តបន្ទាយមានជ័យ**
**Project Office, Banteay Meanchey**
Provincial Department of Agriculture, Village II,
Kampong Svay Commune, Sereysophorn District, Banteay Meanchey
Tel/Fax: 054 710 344 - P.O Box: 105 Banteay Meanchey
Email: banteay.meanchey.office@ecosorn.org

**ការិយាល័យគំរោងខេត្តបាត់ដំបង**
**Project Office, Battambang**
Provincial Department of Agriculture, National road #5,
Romchek 4 village, Rattanak commune, Battambang.
Tel/Fax: 053 730 398 - P.O Box: 404 Battambang
Email: battambang.office@ecosorn.org

**ការិយាល័យសម្របសម្រួលភ្នំពេញ**
**Coordination Office, Phnom Penh**
Ministry of Agriculture, Forestry and Fisheries
#200, Norodom Blvd, Chamkarmon, Phnom Penh
Suite: #19-21, AIDOC building 1st floor - Tel/Fax: 023 223 786
Email: phnom.penh.office@ecosorn.org
**website: www.ecosorn.org**


**គណៈកម្មាធិការដឹកនាំគំរោង**
Project Steering Committee

MAFF MRD MORAM MOI MWA MLMUPC


This project is implemented by ECOSORN and funded by the European Union and the Royal Government of Cambodia



The views expressed in this publication do not necessarily reflect the views of the European Commission